# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង លើផ្ទៃដីទំហំ ៦៣(ហុកសិបបី)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង សម្រាប់ផ្តល់ជូនក្រុមហ៊ុន ច័ន្ទ រតន៍ គ្រុប ដើម្បីចិញ្ចឹមក្តាម បង្គា ត្រី និងចូលរួមក្នុងការអភិរក្សព្រៃកោងកាងតាមតំបន់ឆ្នេរសមុទ្រ ដែលមានលិខិតលេខ ១៤៨ សជណ.កស ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ ព្រមទាំងមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់ជាមួយ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទីបង្ហាញទីតាំងក្រុមហ៊ុន ច័ន្ទ រតន៍ គ្រុប ធ្វើការចិញ្ចឹមក្តាម បង្គា ត្រី និងអភិរក្សព្រៃកោងកាង លើផ្ទៃដីសរុប ៦៣ហិកតា ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ភូមិសាស្ត្រឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង




អនុក្រឹត្យ លេខ:...៣២...អនក្រ.បក

ចុះថ្ងៃទី.២២... ខែ ...កុម្ភៈ... ឆ្នាំ.២០១១

**សញ្ញាសំគាល់**

- ● ចំណុចនិយាមកា
- ▭ ទីតាំងរបស់ក្រុមហ៊ុន
- ▭ ព្រំប្រទល់តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង

| Id | N | X | Y |
|---|---|---|---|
| 1 | A | 353768 | 1220068 |
| 2 | B | 353988 | 1220207 |
| 3 | C | 354340 | 1220118 |
| 4 | D | 354369 | 1220052 |
| 5 | E | 354475 | 1220024 |
| 6 | F | 354619 | 1219792 |
| 7 | G | 354701 | 1219566 |
| 8 | H | 354322 | 1219468 |
| 9 | I | 354342 | 1219410 |
| 10 | J | 354603 | 1219364 |
| 11 | K | 354719 | 1219364 |
| 12 | L | 354638 | 1219038 |
| 13 | M | 354614 | 1218837 |
| 14 | N | 354499 | [illegible] |
| 15 | O | 354441 | 1218904 |
| 16 | P | 354374 | 1218910 |

មាត្រដ្ឋាន 1:12,000

0 Kilometers

Coordinate System: UTM
Unit: Metter
Datum: Indian 1960
Zone: 48 N